**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ: ៥៥៣ មស. ក្រង

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ** ៖ ផែនការជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិល សម្រាប់ឆ្នាំ២០១៥។

**យោង** ៖-សារាចរលេខ០១ ស.រ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីគោលការណ៍ជ្រើសរើសបុគ្គលក្នុងក្របខណ្ឌរដ្ឋ និងគោលការណ៍ជ្រើសរើសបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួង ស្ថាប័ននានា

-សារាចរលេខ០១ ស.រ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត ក្នុងឆ្នាំ២០១៥

-របាយការណ៍ក្របខណ្ឌឆ្នាំ២០១៤ និងគម្រោងផែនការក្របខណ្ឌឆ្នាំ២០១៥ របស់ក្រសួង ស្ថាប័ន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានអនុញ្ញាតជាគោលការណ៍ក្នុងការជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិល សម្រាប់ផែនការឆ្នាំ២០១៥ តាមចំនួនស្មើនឹងចំនួនមន្ត្រីរាជការស៊ីវិលដែលបាត់បង់ពីក្របខណ្ឌដូចក្រសួង ស្ថាប័ន បានរាយការណ៍មកក្រសួងមុខងារសាធារណៈ តាមចំនួនដូចខាងក្រោម៖

ឯកតា៖នាក់

| ល.រ | ក្រសួង ស្ថាប័ន | ចំនួនមន្ត្រីរាជការដែលបាត់បង់ពីក្របខណ្ឌ | | | ក្របខណ្ឌផ្តល់ជូន ឆ្នាំ២០១៥ |
|---|---|---|---|---|---|
| | | ចូលនិវត្តន៍ ២០១៤ | លុបឈ្មោះ ២០១៤ | បាត់បង់សម្បទាវិជ្ជាជីវៈ ២០១៤ | |
| ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | ២៦ | | | ២៦ |
| ២ | ព្រះបរមរាជវាំង | ៥ | ១ | | ៦ |
| ៣ | ទេសចរណ៍ | ១២ | | | ១២ |
| ៤ | អប់រំ យុវជន និងកីឡា | ២.១៥៩ | ៨៥៦ | | ៣.០១៥ |
| ៥ | ពាណិជ្ជកម្ម | ៤៣ | ២១ | | ៦៤ |
| ៦ | អភិវឌ្ឍន៍ជនបទ | ៤៤ | ៦ | | ៥០ |
| ៧ | វប្បធម៌ និងវិចិត្រសិល្បៈ | ៩៤ | ១១ | ២ | ១០៧ |
| ៨ | បរិស្ថាន | ១៥ | ១៨ | | ៣៣ |
| ៩ | ឧស្សាហកម្ម និងសិប្បកម្ម | ២៨ | ៨ | | ៣៦ |
| ១០ | រ៉ែ និងថាមពល | ៨ | | | ៨ |
| ១១ | ធនធានទឹក និងឧតុនិយម | ៣៣ | ៧ | | ៤០ |
| ១២ | កិច្ចការនារី | ១៩ | | | ១៩ |
| ១៣ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១៤ | | | ១៤ |
| ១៤ | មហាផ្ទៃ | ២៦៦ | ៤៧ | ៨៧ | ៤០០ |
| ១៥ | ព័ត៌មាន | ៧១ | | | ៧១ |

| | | | | | |
|---|---|---|---|---|---|
| ១៦ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៥៩ | ១១៨ | | ២៧៧ |
| ១៧ | យុត្តិធម៌ | ១០ | ២២ | ២ | ៣៤ |
| ១៨ | ផែនការ | ២៥ | | | ២៥ |
| ១៩ | សុខាភិបាល | ៤០២ | ៣១ | | ៤៣៣ |
| ២០ | ធម្មការ និងសាសនា | ៦ | | | ៦ |
| ២១ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១១ | ៥ | ២ | ១៨ |
| ២២ | ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ៥ | ១ | | ៦ |
| ២៣ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៣២ | ២ | | ៣៤ |
| ២៤ | ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៣១ | | | ៣១ |
| ២៥ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១២១ | ៥៥ | | ១៧៦ |
| ២៦ | មុខងារសាធារណៈ | ១១ | ១ | | ១២ |
| ២៧ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២០ | ១៤ | | ៣៤ |
| ២៨ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ៥ | ២ | | ៧ |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ៣ | | | ៣ |
| | **សរុបរួម** | ៣.៦៧២ | ១.២២៦ | ៨៣ | ៥.០០១ |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាចាត់ចែងរៀបចំធ្វើការប្រឡងប្រជែងជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឲ្យចូលបម្រើការងារ ដើម្បីបំពេញមុខតំណែងទំនេរ និងសេចក្តីត្រូវការដែលមានពិតប្រាកដនៅតាមអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវយកចិត្តទុកដាក់ដល់បេក្ខភាពជាជនពិការដែលមានសមត្ថភាពសមស្រប ២% នៃចំនួនក្របខណ្ឌសរុបរបស់សាមីក្រសួង ស្ថាប័ន ហើយត្រូវមានបេក្ខនារីជាប់ជា ស្ត្រីពី ២០% ទៅ ៥០% នៃចំនួនក្របខណ្ឌដែលទទួលបានប្រចាំឆ្នាំ។ សូមគ្រប់ក្រសួង ស្ថាប័ន មេត្តារៀបចំស្នើសុំមន្ត្រីតំណាងក្រសួងមុខងារសាធារណៈ ចូលរួមក្នុងដំណើរការប្រឡងឲ្យបានមុនពេលរៀបចំបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសប្រចាំឆ្នាំ ដើម្បីក្រសួងមុខងារសាធារណៈមានលទ្ធភាពចូលរួមសហការ ចាប់តាំងពីដំណាក់កាលដំបូង។

សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រដ្ឋមន្ត្រី

ពេជ្រ ប៊ុនធិន

**ចម្លងជូន៖**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ កាលប្បវត្តិ



អាសយដ្ឋាន: (កែងផ្លូវវ៉ែងជាលេខ២០០៤) ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៨០១